# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី៤ ខែមិនា ឆ្នាំ២០១៦

## ជប៉ុនផ្តល់ ៣៣៨,៩៦៣ដុល្លារអាមេរិក ដើម្បីកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រឹងទីផ្សារនៃផលិតផលសរីរាង្គរបស់សហគមន៍កសិកម្ម

ក្រោមគ្រោងការណ៍នៃជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាសរុបចំនួន ៣៣៨,៩៦៣ដុល្លារអាមេរិក ដល់ក្រុមអ្នកស្ម័គ្រចិត្តអន្តរជាតិរបស់យ៉ាម៉ាហ្គាតា (អាយ.វី.វ៉ាយ)។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកស្រី ម៉ាត់ស៊ូអ៊ូរ៉ា អាយូមិ នាយិកាអង្គការ អាយ.វី.វ៉ាយ នៅស្ថានទូតជប៉ុន សម្រាប់គម្រោងកាត់បន្ថយភាពក្រីក្រតាមរយៈការពង្រឹងទីផ្សារនៃផលិតផលសរីរាង្គរបស់សហគមន៍កសិកម្មក្នុងខេត្តចំនួន២ "ដំណាក់កាលទី១"។

ក្នុងគម្រោងនេះ អង្គការ អាយ.វី.វ៉ាយ នឹងកែលម្អសមត្ថភាពគ្រប់គ្រងសហគមន៍ ក៏ដូចជាពង្រឹងប្រព័ន្ធទីផ្សារស្រូវសរីរាង្គរបស់សហគមន៍កសិកម្ម ក្នុងខេត្តព្រះវិហារ។ រីឯនៅក្នុងខេត្តស្វាយរៀង អង្គការ អាយ.វី.វ៉ាយ នឹងបន្តជួយសហគមន៍ផ្គត់ផ្គង់កសិផលស្វាយរៀង (SAC) ដោយធ្វើការសាងសង់នូវមជ្ឈមណ្ឌលទីផ្សារសហគមន៍ថ្មីមួយ ដើម្បីចែកចាយលក់បន្លែអោយកាន់តែមានប្រសិទ្ធភាព។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ត្រូវបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ ២០០២មក រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង ២៥ លានដុល្លារអាមេរិក ដល់គម្រោងចំនួន ៩២ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល និងសកម្មភាពបោសសំអាតមីន។ គម្រោងដែលត្រូវបានចុះហត្ថលេខានាថ្ងៃនេះ គឺជាគម្រោងទី៥ តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៥ របស់ជប៉ុន (មេសា២០១៥ ដល់ មិនា ២០១៦)។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*